**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៧៨៩៣ ព.ណ.ការម

ថ្ងៃចន្ទ ១៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩

## ជម្រាបមក
**លោក/លោកស្រីប្រធាន ក្រុមហ៊ុន អ អិម អេ (ខេមបូឌា)**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ លើផលិតផលរថយន្ត គ្រឿងបន្លាស់ និងគ្រឿងតុបតែងម៉ាក "FORD" និង Ford ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា)**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា)** ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Ford Motor Company ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៣០៦៩/០៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៣០៧០/០៩ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលរថយន្ត គ្រឿងបន្លាស់ និងគ្រឿងតុបតែងពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា)** ដែលទទួលបានពីក្រុមហ៊ុន Ford Motor Company ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែល ក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Ford Motor Company ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

**ចម្លងជូន:**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469